# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋសភា**

លេខ ...................... .រ.ស.

## សូមជម្រាបជូន
## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**តាមរយៈ** : សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា

**កម្មវត្ថុ** : ការផ្សព្វផ្សាយព័ត៌មានមិនពិត ពីសំណាក់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និង សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ។

**យោង** : _មាត្រា៩៦ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
_លិខិតចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៩ របស់សម្តេចទាំងបី ផ្ញើថ្វាយព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ**

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំជាអ្នកតំណាងរាស្ត្រ ដូចមានរាយនាមខាងក្រោម សូមសួរទៅរាជរដ្ឋាភិបាលថា តើមានការផ្សព្វផ្សាយព័ត៌មានមិនពិតឬទេ ក្នុងលិខិតដែលសម្តេចទាំងបី បានផ្ញើថ្វាយព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលមានខ្លឹមសារថា "រហូតមកដល់ពេលនេះ ពុំមានប្រជាកសិករខ្មែរណាម្នាក់បាត់បង់ដីស្រែរបស់ពួកគាត់ឡើយ ដោយហេតុថា ក្រុមបច្ចេកទេសចំរុះកំពុងធ្វើការបោះបង្គោលព្រំដែនប៉ុណ្ណោះ ដោយពុំទាន់បានធ្វើការខណ្ឌសីមានៅឡើយ ហើយភាគីទាំងពីរមិនបានហាមឃាត់ប្រជាកសិករទាំងសងខាង បញ្ឈប់ការធ្វើស្រែចំការរបស់ពួកគាត់ទេ" ?

យោងតាមខ្លឹមសារខាងលើនៃលិខិតរបស់សម្តេចទាំងបី តើនេះជាការផ្សព្វផ្សាយព័ត៌មានមិនពិតឬ បន្ទាប់ពីកសិករពីរនាក់ គឺលោក **ព្រាំ ជា** និងលោកស្រី **មាស ស្រី** នៅឃុំសំរោង ស្រុកចន្ទ្រា ខេត្តស្វាយរៀង ត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារ រយៈពេលមួយឆ្នាំ ដោយសារតែហ៊ានចេញមុខការពារដីស្រែរបស់ខ្លួន ហើយត្រូវបានដោះលែងវិញ កាលពីថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១០ ?

តើកសិករទាំងពីររូបនេះ គឺជាសាក្សី ឬជាភស្តុតាងរស់នៃការបាត់បង់ដីស្រែ ដោយការបោះបង្គោលព្រំដែនឬ?

អាស្រ័យដូចបានជម្រាបជូនខាងលើ យើងខ្ញុំសង្ឃឹមថា រាជរដ្ឋាភិបាលនឹងឆ្លើយនូវសំណួរខាងលើនេះឲ្យបានច្បាស់លាស់ តាមការគួរ ។

សូមសម្តេចនាយករដ្ឋមន្ត្រីទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រ អំពីយើងខ្ញុំ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី..២៦.. ខែតុលា ឆ្នាំ២០១០*

**ក្រុមអ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី**

**បានឃើញ និងបញ្ជូនមក**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

"ដើម្បីពិនិត្យ"

*ភ្នំពេញ, ថ្ងៃទី............ខែតុលា ឆ្នាំ២០១០*

**ចម្លងជូន :**

_សម្តេចព្រះមហាវីរក្សត្រ

_ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា


វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : ( ៨៥៥-២៣ ) ២១៣ ៥៣៥, ២២០ ៦២៨, ទូរសារ : ( ៨៥៥-២៣ ) ២២០ ៦២៩